# ការរង់ចាំព្រះអម្ចាស់ ៖ នោះសូមតាមព្រះហឫទ័យទ្រង់ចុះ

*ដោយអែលឌើរ រ៉ូប៊ើត ឌី ហែល*
*នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

នៅព្រឹកថ្ងៃឈប់សម្រាកនេះ យើងសូមថ្លែងអំណរគុណ និងថ្លែងទីបន្ទាល់ពីការពិតថា ព្រះអង្គសង្គ្រោះយើងមានព្រះជន្មរស់ ។ ដំណឹងល្អទ្រង់ត្រូវបានស្ដារឡើងវិញ តាមរយៈព្យាការី យ៉ូសែប ស៊្មីធ ។ ព្រះគម្ពីរ មរមនជាព្រះគម្ពីរពិត ។ យើងត្រូវបានដឹកនាំដោយព្យាការីនៅរស់សព្វថ្ងៃ គឺប្រធាន ថូម៉ាស អេស ម៉នសុន។ សំខាន់ជាងនេះទៀត យើងសូមថ្លែងជាសាក្សីដ៏ឱឡារិកពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និង ពរជ័យដ៏អស់កល្បដែលកើតមកពីដង្វាយធួននោះ។ អំឡុងពេលប៉ុន្មានខែមុននេះ ខ្ញុំបានមានឱកាសសិក្សា និងរៀនបន្ថែមទៀតពីពលិកម្មដែលធ្វើឲ្យធួនរបស់ព្រះអង្គ

សង្គ្រោះយើង និងពីរបៀបដែលទ្រង់បានរៀបចំខ្លួន ដើម្បីធ្វើការប្រទានឲ្យដ៏អស់កល្បដល់យើងម្នាក់ៗ ។

ការរៀបចំខ្លួនរបស់ទ្រង់ បានចាប់ផ្ដើមក្នុងជីវិតមុនផែនដី ខណៈដែលទ្រង់បានរង់ចាំព្រះបិតាទ្រង់ ដោយមានបន្ទូលថា « សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គបានសម្រេច ហើយសូមឲ្យសិរីល្អរបស់ព្រះអង្គបានជារបស់ផងព្រះអង្គរហូត » ។[1] ចាប់ផ្ដើមពីគ្រានោះរហូតមកដល់សព្វថ្ងៃ ទ្រង់បានប្រើសិទ្ធិជ្រើសរើសរបស់ទ្រង់ ដើម្បីទទួល ហើយអនុវត្តនូវផែនការរបស់ព្រះវរបិតាសួគ៌ ។ ព្រះគម្ពីរបង្រៀនយើងថា ក្នុងយុវវ័យទ្រង់ ទ្រង់បានយាងចេញទៅធ្វើ « កិច្ចការរបស់បិតាទ្រង់ »[2] ហើយ « បានទទ្ទឹងដល់ព្រះអម្ចាស់ចាំពេលនៃការងារបម្រើរបស់ទ្រង់មកដល់ »[3] លុះដល់ព្រះជន្ម 30 ទ្រង់បានរងទុក្ខនឹងការល្បួងដ៏លំបាក តែទ្រង់បានជ្រើសរើសបន្តស៊ូទ្រាំ ដោយមានបន្ទូលថា « សាតាំងអើយ ចូរថយទៅក្រោយអញទៅ »[4] ក្នុងសួនច្បារគែតសេម៉ានី ទ្រង់បានទុកចិត្តលើព្រះបិតាទ្រង់ ដោយប្រកាសថា « ប៉ុន្តែកុំតាមចិត្តទូលបង្គំឡើយ សូមតាមតែព្រះហឫទ័យទ្រង់វិញ »[5] រួចហើយបានប្រើសិទ្ធិជ្រើសរើសទ្រង់ ដើម្បីរងទុក្ខសម្រាប់អំពើបាបយើង ។ តាមរយៈការធ្វើឲ្យអាប់ឱនកិត្តិយសក្នុងការកាត់ទោសជាសាធារណៈ និងការឈឺចាប់នៃការឆ្កាង នោះទ្រង់បានរង់ចាំព្រះបិតាទ្រង់ ដោយមានឆន្ទៈដើម្បី « ត្រូវរបួសដោយព្រោះអំពើរំលងទាំងឡាយរបស់យើង ...[ ហើយ ] ត្រូវបានវាយដំដោយព្រោះអំពើទុច្ចរិតទាំងឡាយរបស់យើង » ។[6] សូម្បីពេលទ្រង់បានស្រែកឡើងថា « ឱព្រះអង្គៗនៃទូលបង្គំអើយ ហេតុអ្វីបានជាទ្រង់ចោលទូលបង្គំ ? »[7] ទ្រង់បានរង់ចាំព្រះបិតាទ្រង់ ---ដោយប្រើសិទ្ធិជ្រើសរើសទ្រង់ ដើម្បីអភ័យទោសដល់ខ្មាំងសត្រូវទ្រង់[8] សម្លឹងមើលមាតាទ្រង់[9] និងកាន់ខ្ជាប់ដល់ចុងបំផុតរហូតព្រះជន្ម និងបេសកកម្មនៃជីវិតរមែងស្លាប់ទ្រង់ត្រូវបានបញ្ចប់ ។[10]

ជារឿយៗ ខ្ញុំធ្លាប់ពិចារណាថា ហេតុអ្វីបានជាព្រះរាជបុត្រានៃព្រះ និងពួកព្យាការីដ៏បរិសុទ្ធរបស់ទ្រង់ និងរាល់ពួកបរិសុទ្ធស្មោះត្រង់មាននូវការសាកល្បង និងទុក្ខព្រួយ សូម្បីពេលដែលពួកគេកំពុងតែព្យាយាមធ្វើតាមព្រះទ័យរបស់ព្រះវរបិតាសួគ៌នោះ ?

ខ្ញុំបានគិតពី យ៉ូសែប ស៊្មីធ ដែលបានរងទុក្ខដោយជម្ងឺកាលពីក្មេង និងការបៀតបៀនពេញមួយជីវិតលោក ។ ដូចជាព្រះអង្គសង្គ្រោះផងដែរ លោកស្រែកឡើងថា « ឱព្រះអង្គអើយ តើព្រះអង្គគង់នៅទីណា ? »[11] តែសូម្បីពេលលោកនៅឯកោតែម្នាក់ឯងក្ដី ក៏លោកបានប្រើសិទ្ធិជ្រើសរើសលោកដើម្បីរង់ចាំព្រះអម្ចាស់ ហើយអនុវត្តនូវព្រះទ័យនៃព្រះវរបិតាសួគ៌លោកដែរ ។

ខ្ញុំគិតពីពួកអ្នកត្រួសត្រាយផ្លូវរបស់យើង ដែលត្រូវបានបណ្ដេញពីទីក្រុង ណៅវូ ហើយដើរកាត់វាលទំនាប ---ដោយប្រើសិទ្ធិជ្រើសរើសរបស់ខ្លួន ដើម្បីធ្វើតាមព្យាការី សូម្បីពេលពួកគេរងទុក្ខដោយជម្ងឺ ការអត់ឃ្លាន និងសេចក្ដីស្លាប់ ។ ហេតុអ្វីបានជាពួកគេជួបនូវទុក្ខព្រួយដ៏អាក្រក់បែបនេះ ? តើចុងបញ្ចប់នឹងបានអ្វីទៅ ? តើសម្រាប់គោលបំណងអ្វីទៅ ?

ពេលយើងសួរសំនួរទាំងនេះ យើងដឹងថា គោលបំណងនៃជីវិតយើងលើផែនដី គឺដើម្បីរីកចម្រើន អភិវឌ្ឍ និងមានភាពរឹងមាំដោយឆ្លងកាត់បទពិសោធន៍របស់យើង ។ តើយើងធ្វើការនេះយ៉ាងដូចម្ដេច ? ព្រះគម្ពីរបានផ្ដល់ចម្លើយមួយដល់យើងជាឃ្លាមួយដ៏សាមញ្ញថា ៖ យើង «រង់ចាំព្រះអម្ចាស់ » ។[12] ការល្បួង និងការសាកល្បងបានផ្ដល់ដល់យើងគ្រប់ៗគ្នា ។ ឧបសគ្គក្នុងជីវិតរមែងស្លាប់ទាំងនេះអនុញ្ញាតឲ្យយើង និងព្រះវរបិតាសួគ៌ដើម្បីមើលឃើញថាតើយើងនឹងប្រើសិទ្ធិជ្រើសរើសរបស់យើងដើម្បីធ្វើតាមព្រះរាជបុត្រាទ្រង់ដែរឬទេ ។ ទ្រង់ជ្រាបរួចហើយ ហើយយើងមានឱកាសរៀនថា មិនថាកាលៈទេសៈយើងលំបាកប៉ុណ្ណានោះទេ « គ្រប់ការណ៍ទាំងនេះនឹងផ្ដល់ការពិសោធន៍ដល់[ យើង ] ហើយនឹងទៅជាការល្អដល់[ យើង ] » ។[13]

តើនេះមានន័យថាយើងនឹងយល់ពីការលំបាករបស់យើងជានិច្ចមែនទេ ? ពេលខ្លះ យើងទាំងអស់គ្នាគ្មានហេតុផលដើម្បីទូលសួរថា « ឱព្រះអង្គអើយ តើព្រះអង្គនៅទីណា » គ្រប់គ្នានោះទេ ?[14] មែនហើយ ! ពេលស្វាមី ឬភរិយាស្លាប់ នោះដៃគូនឹងឆ្ងល់ថាតើព្រះនៅទីណា ។ ពេលការលំបាកខាងហិរញ្ញ

វត្ថុកើតមានក្នុងគ្រួសារមួយ នោះឪពុកនឹងសួរថាព្រះនៅទីណា ។ ពេលកូនដើរខុសផ្លូវ នោះឪពុកម្តាយនឹងស្រែកឡើងដោយភាពសោកសៅ ។ មែនហើយ « ទឹកភ្នែកនឹងមាននៅជាប់អស់មួយយប់ក៏បាន តែព្រឹកឡើងគង់នឹងមានសេចក្តីអំណរឡើង » ។[15] រួចហើយ នៅពេលចាប់ផ្តើមនៃក្តីជំនឿ និងការយល់ដឹងដ៏កើនឡើងរបស់យើង នោះយើងនឹងក្រោកឡើង ហើយជ្រើសរង់ចាំព្រះអម្ចាស់ ដោយនិយាយថា « សូមតាមព្រះហឫទ័យទ្រង់ចុះ » ។[16]

អញ្ចឹង តើការរង់ចាំព្រះអម្ចាស់មានន័យយ៉ាងណា ? ក្នុងព្រះគម្ពីរ ពាក្យថា *រង់ចាំ* មានន័យថា សង្ឃឹម ទន្ទឹងចាំ និងទុកចិត្ត ។  ការសង្ឃឹម និងទុកចិត្តលើព្រះអម្ចាស់តម្រូវឲ្យមានក្តីជំនឿ ការស៊ូទ្រាំ ភាពរាបសា ស្លូត និងចិត្តអត់ធ្មត់ ក្នុងការគោរពព្រះបញ្ញត្តិ និងការកាន់ខ្ជាប់ដល់ចុងបំផុត ។

ការរង់ចាំព្រះអម្ចាស់មានន័យថា ការដាំគ្រាប់ពូជនៃក្តីជំនឿ ហើយថែទាំវា « ដោយសេចក្តីព្យាយាមដ៏ខ្លាំងក្លា និង... សេចក្តីអត់ធន់ » ។[17]

វាមានន័យថា ជាការអធិស្ឋានដូចជាព្រះអង្គសង្គ្រោះបានធ្វើ -- ចំពោះព្រះជាព្រះវរបិតាសួគ៌របស់យើង --ដោយទូលថា « សូមឲ្យព្រះហឫទ័យ ទ្រង់បានសម្រេចនៅផែនដី ដូចនៅស្ថានសួគ៌ដែរ » ។ នេះគឺជាការអធិស្ឋានដែលយើងទូលថ្វាយដោយអស់ពីដួងចិត្ត នៅក្នុងព្រះនាមព្រះអង្គសង្គ្រោះរបស់យើង ព្រះយេស៊ូវគ្រីស្ទ ។

ការរង់ចាំព្រះអម្ចាស់មានន័យថា ការពិចារណាក្នុងដួងចិត្តយើង និង « [ ការ ] ទទួលព្រះវិញ្ញាណបរិសុទ្ធ » ដើម្បីយើងអាចដឹង « នូវគ្រប់អ្វីទាំងអស់ដែល [ យើង ] ត្រូវធ្វើ » ។[18]

ពេលយើងធ្វើតាមការបំផុសពីព្រះវិញ្ញាណ នោះយើងរកឃើញថា « សេចក្តីលំបាកបង្កើតឲ្យមានសេចក្តីទ្រាំទ្រ » [19] ហើយយើងរៀន « ស៊ូនៅក្នុងសេចក្តីអត់ធន់...រហូតដល់[ យើង ]_ បានល្អឥតខ្ចោះ » ។[20]
ការរង់ចាំព្រះអម្ចាស់មានន័យថា ការ « ឈររឹងប៉ឹង » [21] ហើយ « ឈានទៅមុខ » ក្នុងក្តីជំនឿ « ដោយមានការភ្លឺថ្លានៃសេចក្តីសង្ឃឹមដ៏ឥតខ្ចោះ »  ។[22]

វាមានន័យថា ការ « ពឹងផ្អែកទៅលើតែព្រះគុណនៃព្រះគ្រីស្ទ » [23] និង « ដោយព្រះគុណរបស់ទ្រង់ដើម្បីជួយ [យើង] ឲ្យនិយាយថា ៖ ឱព្រះអម្ចាស់អើយ សូមឲ្យបានសម្រេចតាមតែព្រះហឫទ័យរបស់ទ្រង់ចុះ »។[24]

ពេលយើងរង់ចាំព្រះអម្ចាស់ យើងត្រូវតែ « មុតមាំក្នុងការកាន់ព្រះបញ្ញត្តិទាំងឡាយ » ។[25] ដោយដឹងថា យើង « នឹងបានសម្រាកពីគ្រប់អស់ទាំងការទុក្ខវេទនា  [ របស់យើងនៅថ្ងៃណាមួយ ] » ។[26]

ហើយយើង មិន « បោះបង់ចោលសេចក្តីក្លាហាន  [ របស់យើង ] ...ឡើយ » [27] ថា « គ្រប់ការណ៍ទាំងអស់ដែល  [ យើង ] ត្រូវបានរងទុក្ខ នោះនឹងផ្សំគ្នាសម្រាប់សេចក្តីល្អដល់ [ យើង ]  » ។[28]

ទុក្ខលំបាកទាំងនោះនឹងកើតឡើងក្នុងគ្រប់ទ្រង់ទ្រាយ និងកម្រិត ។ បទពិសោធន៍របស់យ៉ូប ធ្វើឲ្យយើងចងចាំពីអ្វីដែលយើងអាចតម្រូវឲ្យមាន ដើម្បីធ្វើការស៊ូទ្រាំ ។ យ៉ូបបាត់បង់ទ្រព្យសម្បត្តិរបស់គាត់ទាំងអស់ រួមទាំង ដីធ្លី ផ្ទះ សត្វពាហនៈ សមាជិកគ្រួសារ កេរ្តិ៍ឈ្មោះ សុខភាព ព្រមទាំងសុខុមាលភាពខាងផ្លូវចិត្តរបស់គាត់ផងដែរ ។ តែ គាត់បានរង់ចាំព្រះអម្ចាស់ ហើយបានថ្លែងទីបន្ទាល់ផ្ទាល់ខ្លួនដ៏មានឥទ្ធិពលមួយថា ៖

« ប៉ុន្តែឯខ្ញុំៗដឹងថាអ្នកដែលប្រោសលោះខ្ញុំទ្រង់មានព្រះជន្មរស់នៅ ហើយដល់ជាន់ក្រោយ ទ្រង់នឹងមកឈរនៅលើផែនដី ហើយក្រោយដែលសំបកកាយនេះ ត្រូវរលាយទៅ គឺក្រៅពីរាងកាយ នោះខ្ញុំនឹងបានឃើញព្រះ » ។[29]

« ទោះបីទ្រង់សម្លាប់ខ្ញុំក៏ដោយ គង់តែខ្ញុំនឹងទុកចិត្តដល់ទ្រង់»។[30] សូម្បី ជាមួយនឹងគំរូដ៏ល្អរបស់យ៉ូប ពួកព្យាការី និងព្រះអង្គសង្គ្រោះ យើងនៅតែរកឃើញថា វាជាការលំបាកក្នុងការរង់ចាំព្រះអម្ចាស់ ជាពិសេសពេលយើងមិនអាចយល់យ៉ាងពេញលេញពីផែនការ និងគោលបំណងរបស់ទ្រង់សម្រាប់យើង ។ ការយល់ដឹងនោះជាញឹកញាប់ត្រូវបានប្រទានឲ្យ
« មួយបន្ទាត់ម្តងៗ [និង] មួយសិក្ខាបទម្តងៗ » ។[31]

ពេលខ្លះ យើងមិនបានត្រៀមខ្លួនជាស្រេចដើម្បីទទួលទ្រព្យទាំងនេះទេ ។ ក្នុងជីវិតខ្ញុំ ខ្ញុំបានដឹងថា ពេលខ្លះ ខ្ញុំមិនបានទទួលចម្លើយការអធិស្ឋាន ពីព្រោះព្រះអម្ចាស់ជ្រាបថា ខ្ញុំពុំទាន់រៀបចំខ្លួននៅឡើយ ។ ពេលទ្រង់បានឆ្លើយតប ជារឿយៗវាមាន « ឯណេះបន្តិច ឯណោះបន្តិច »[32] ពីព្រោះនោះជាអ្វីដែលអាចទ្រាំទ្របាន ឬជាអ្វីដែលខ្ញុំនឹងធ្វើ ។
ជានិច្ចកាលយើងអធិស្ឋានឲ្យមានចិត្តអត់ធន់ តែយើងចង់បានវាភ្លាមៗ ! កាលពីក្មេង ប្រធាន ដេវីឌ អូ មិកឃេ បានអធិស្ឋានសុំសាក្សីមួយពីសេចក្ដីពិតដ៏ពេញលេញនៃដំណឹងល្អ ។

ច្រើនឆ្នាំក្រោយមក កាលលោកបម្រើបេសកកម្មក្នុងប្រទេស ស្កុតលែន នៅទីបំផុតសាក្សីនោះបានកើតមានឡើង ។ ក្រោយមកទៀតលោកបានសរសេរថា « វាជាការអះអាងមួយចំពោះខ្ញុំថា ការអធិស្ឋានដោយស្មោះត្រូវបានឆ្លើយតប ‹ នៅពេលខ្លះ នៅកន្លែងណាមួយ › » ។[33]

យើងអាចនឹងមិនដឹងពីពេល ឬពីរបៀបដែលចម្លើយរបស់ព្រះអម្ចាស់នឹងកើតមានទេ តែតាមពេល និងតាមរបៀបទ្រង់ នោះចម្លើយនឹងកើតមាន ។ សម្រាប់ចម្លើយមួយចំនួន យើងប្រហែលជាត្រូវរង់ចាំរហូតដល់ជីវិតក្រោយ ។ នេះប្រហែលជាពិតសម្រាប់ការសន្យាមួយចំនួនក្នុងពរជ័យលោកអយ្យកោយើង និងពរជ័យមួយចំនួនចំពោះសមាជិកគ្រួសារ ។ ចូរយើងកុំបោះបង់ចោលព្រះអម្ចាស់ឡើយ ។ ពរជ័យរបស់ទ្រង់គឺអស់កល្ប ពុំមែនបណ្ដោះអាសន្នទេ ។

ការរង់ចាំព្រះអម្ចាស់ ផ្ដល់ឱកាសដ៏មានតម្លៃបំផុតដល់យើង ដើម្បីរកឃើញថា មានមនុស្សជាច្រើនដែលកំពុងរង់ចាំយើង ។ កូនចៅយើងកំពុងរង់ចាំយើង ដើម្បីបង្ហាញភាពអត់ធន់ ក្ដីស្រឡាញ់ និងការយល់ចិត្តចំពោះពួកគេ ។ ឪពុកម្ដាយយើងកំពុងរង់ចាំយើង ដើម្បីបង្ហាញពីការដឹងគុណ និងក្ដីមេត្តា ។ បងប្អូនប្រុសស្រីរបស់យើងកំពុងរង់ចាំយើងឲ្យមានចិត្តអត់ធ្មត់ ចិត្តមេត្តា និងអភ័យទោស ។ ស្វាមី ឬភរិយាយើងកំពុងរង់ចាំយើងឲ្យស្រឡាញ់ពួកគេ ដូចដែលព្រះអង្គសង្គ្រោះបានស្រឡាញ់យើងម្នាក់ៗ ។

ពេលយើងស៊ូទ្រាំនឹងការរងទុក្ខខាងរូបកាយ យើងដឹងថាមានមនុស្សប៉ុន្មាននាក់ដែលកំពុងរង់ចាំយើងម្នាក់ៗ ។ ចំពោះស្ត្រីទាំងឡាយដូចជា ម៉ារី និង ម៉ាថា ចំពោះរាល់សាសន៍សាម៉ារីដែលបម្រើដល់អ្នកឈឺ ជួយដល់អ្នកទន់ខ្សោយ និងមើលថែដល់អ្នកជំងឺខាងផ្លូវចិត្ត និងរូបកាយ ខ្ញុំសូមសម្ដែងការដឹងគុណពីព្រះវរបិតាសួគ៌ជាទីស្រឡាញ់ និងព្រះរាជបុត្រាសំណប់ទ្រង់ ។

ក្នុងការបម្រើប្រចាំថ្ងៃរបស់យើងដូចជាព្រះគ្រីស្ទ អ្នកកំពុងរង់ចាំព្រះអម្ចាស់ និងកំពុងធ្វើតាមព្រះទ័យរបស់ព្រះវរបិតាសួគ៌ ។ ការអះអាងរបស់ទ្រង់ចំពោះអ្នកគឺច្បាស់ថា ៖ « ដែលអ្នករាល់គ្នាធ្វើការទាំងនោះ ដល់អ្នកតូចបំផុតក្នុងពួកបងប្អូនយើងនេះ នោះឈ្មោះថាបានធ្វើដល់យើងដែរ » ។[34] ទ្រង់ជ្រាបពីការលះបង់ និងទុក្ខសោករបស់អ្នក ។ ទ្រង់ស្ដាប់ឮការអធិស្ឋានអ្នក ។ ក្ដីសុខសាន្ត និងទីសម្រាកទ្រង់នឹងក្លាយជារបស់អ្នក បើអ្នកបន្តរង់ចាំទ្រង់ដោយក្ដីជំនឿ ។

យើងគ្រប់រូប គឺត្រូវបានព្រះអម្ចាស់សព្វព្រះទ័យលើសពីអ្វីដែលអាចយល់ ឬស្រមៃដល់ទៅទៀត ។ ចូរយើងមានចិត្តល្អចំពោះគ្នាទៅវិញទៅមក និងចំពោះខ្លួនយើង ។ ចូរយើងចងចាំថា ពេលយើងរង់ចាំព្រះអម្ចាស់ យើងនឹងប្រែក្លាយជា « អ្នកបរិសុទ្ធវិញ តាមរយៈដង្វាយធួន[ទ្រង់] ...ងាយប្រដៅ ស្លូតបូត ទាបរាបសា អត់ឱន ពោរពេញទៅដោយសេចក្ដីស្រឡាញ់ ព្រមទទួលនូវអ្វីៗទាំងអស់ដែលព្រះអម្ចាស់ទ្រង់ទតឃើញថាល្អ ដូចជាកូនក្មេងព្រមធ្វើតាមឪពុកខ្លួនដូច្នោះ » ។ [35]

នេះជាការគោរពរបស់ព្រះអង្គសង្គ្រោះយើងចំពោះព្រះបិតាទ្រង់ ក្នុងសួនច្បារគេតសាម៉ានី ។ ទ្រង់បានអង្វរដល់ពួកសិស្សទ្រង់ថា « ចាំយាមជាមួយនឹងខ្ញុំសិន » តែពេលទ្រង់ត្រឡប់មករកគេបីលើក ទ្រង់បានឃើញគេកំពុងដេកលក់ ។ ដោយខ្វះភាពជាដៃគូពីសិស្សទាំងនេះ និងដោយគ្មានវត្តមាននៃព្រះបិតាទ្រង់ នោះព្រះអង្គសង្គ្រោះបានជ្រើសរើសរងទុក្ខនូវការឈឺចាប់ និងទុក្ខវេទនា និងការល្បួងគ្រប់បែបយ៉ាង » ។ [36]

ដោយមានទេវតាចាត់មកឲ្យជួយគាំទ្រដល់ទ្រង់ [37] ទ្រង់មិនបានបដិសេធផឹកនូវពែងល្វីងនោះឡើយ ។ [38] ទ្រង់បានរង់ចាំព្រះបិតាទ្រង់ដោយមានបន្ទូលថា « សូមតាមព្រះហឫទ័យទ្រង់ចុះ » [39] ហើយទ្រង់បានសម្រេចបេសកកម្មរបស់ទ្រង់ដោយរាបសា ។[40]

ឥឡូវក្នុងនាមជាសាវកទ្រង់មួយរូបក្នុងចំណោមពួកសាវកទាំងដប់ពីរនាក់ក្នុងថ្ងៃចុងក្រោយនេះ ខ្ញុំសូមអធិស្ឋានថាយើងនឹងត្រូវបានពង្រឹងឲ្យចាំយាមជាមួយនឹងទ្រង់ ហើយរង់ចាំទ្រង់ពេញមួយជីវិតរបស់យើង ។

នាព្រឹកថ្ងៃឈប់សម្រាកនេះ ខ្ញុំសូមសម្តែងការដឹងគុណថាក្នុងការលំបាក ដ៏ធំរបស់ខ្ញុំ និងអ្នក យើងមិនឯកោតែឯងឡើយ ។ ទ្រង់ដែលទតមើលយើង « ទ្រង់នឹងមិនដែលងោកងុយ  ក៏មិនដែលផ្ទំលក់ឡើយ » ។ [41] ពួកទេវតារបស់ទ្រង់នៅទីនេះ និងនៅជ្រុងម្ខាងទៀតគឺ « នៅព័ទ្ធជុំវិញ[យើង] ដើម្បីទ្រ[យើង] ឡើង » ។ [42] ខ្ញុំសូមថ្លែងសាក្សីពិសេសរបស់ខ្ញុំថា ការសន្យាទ្រង់គឺពិត ៖ « អស់អ្នកណាដែលសង្ឃឹមដល់ព្រះអម្ចាស់វិញ នោះនឹងមានកម្លាំងចម្រើនជានិច្ច គេនឹងហើរឡើងទៅលើដោយស្លាប ដូចជាឥន្រ្ទី គេនឹងរត់ទៅឥតដែលហត់ ហើយនឹងដើរឥតដែលល្វើយឡើយ » ។ [43] ចូរយើងរង់ចាំទ្រង់ដោយជឿនទៅមុខក្នុងក្តីជំនឿ ថាយើងនឹងនិយាយក្នុងការអធិស្ឋានរបស់យើងថា « សូមតាមព្រះហឫទ័យទ្រង់ចុះ » [44] ហើយត្រឡប់មករកទ្រង់ដោយកិត្តិយស ។

ក្នុងព្រះនាមនៃព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះយើងជាព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. ម៉ូសេ 4:2 ។
2. លូកា 2:49 ។
3. ការបកប្រែដោយយ៉ូសែប ស្ម៊ីធ ម៉ាថាយ 3:24 ក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ ។
4. លូកា 4:8 ។
5. លូកា  22:42 ។
6. អេសាយ 53:5, ម៉ូសាយ 14:5 ។
7. ម៉ាថាយ 27:46, ម៉ាកុស 15:34 ។
8. សូមមើល លូកា 23:34 ។
9. សូមមើល យ៉ូហាន 19:27 ។
10. សូមមើល យ៉ូហាន 19:30 ។
11. គោលលទ្ធិ និងសេចក្តីសញ្ញា 121:1 ។
12. ទំនុកដំកើង 37:9, 123:2, អេសាយ 8:17, 40:31, នីហ្វៃទី2 18:17 ។
13. គោលលទ្ធិ និងសេចក្តីសញ្ញា 122:7 ។
14. គោលលទ្ធិ និងសេចក្តីសញ្ញា 121:1 ។
15. ទំនុកដំកើង 30:5 ។
16. ម៉ាថាយ 6:10, នីហ្វៃទី3 13:10, សូមមើលផងដែរ ម៉ាថាយ 26:39 ។
17. អាលម៉ា_32:41 ។
18. ម៉ាថាយ 6:10; លូកា 11:2 ។
19. នីហ្វៃទី2 32:5 ។
20. រ៉ូម 5:3 ។
21. គោលលទ្ធិ និងសេចក្តីសញ្ញា 67:13 ។
22. អាលម៉ា 45:17 ។
23. នីហ្វៃទី2 31:20 ។
24. មរ៉ូណៃ 6:4 ។
25. គោលលទ្ធិ និងសេចក្តីសញ្ញា 109:44 ។
26. អាលម៉ា_1:25 ។
27. អាលម៉ា 34:41 ។
28. ហេព្រើរ 10:35 ។
29. គោលលទ្ធិ និងសេចក្តីសញ្ញា 98:3 ។
30. យ៉ូប 19:25--26 ។
31. យ៉ូប 13:15 ។
32. នីហ្វៃទី2 28:30 ។
33. *Teachings of Presidents of the Church: David O. McKay* ( ឆ្នាំ

2003 ) ទំព័រ xviii

34. ម៉ាថាយ 25:40 ។

35. ម៉ូសាយ 3:19 ។

36. អាលម៉ា 7:11 ។

37. សូមមើល លូកា 22:43 ។

38. សូមមើល នីហ្វៃទី3 11:11,គោលលទ្ធិនិងសេចក្ដីសញ្ញា 19:18--19 ។

39. ម៉ាថាយ 26:42 ។

40. សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា 76:107; 88:106; 133:50 ។

41. ទំនុកដំកើង 121:4 ។

42. គោលលទ្ធិ និងសេចក្ដីសញ្ញា 84:88 ។

43. អេសាយ 40:31 ។

44. ម៉ាថាយ 26:42 ។